# ព្រះរាជក្រម

## យើង

នស/រកម/០៨១៥/០១០

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ នាសម័យប្រជុំពេញអង្គលើកទី៧ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៥៦/០០៤/២០១៥ កបធ.ច ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ច្បាប់

## ស្តីពី

## សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងធានាការពារសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាល នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ខ្លួន និងការពារផលប្រយោជន៍សាធារណៈ ព្រមទាំងលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូរវាងសមាគម និង/ឬអង្គការមិនមែនរដ្ឋាភិបាលជាមួយអាជ្ញាធរសាធារណៈ ។

**មាត្រា ២.-**

ច្បាប់នេះមានគោលដៅកំណត់បែបបទទទួលស្គាល់តាមផ្លូវច្បាប់ដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងកំណត់ទំនាក់ទំនងរវាងសមាគម និង/ឬអង្គការមិនមែនរដ្ឋាភិបាលជាមួយអាជ្ញាធរសាធារណៈ ដើម្បីអភិវឌ្ឍសង្គមកម្ពុជា ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានបទប្បញ្ញត្តិច្បាប់ដោយឡែក ដែលចែងផ្សេងពីនេះ ។

**មាត្រា ៤.-**

វាក្យសព្ទដែលប្រើក្នុងច្បាប់នេះមាននិយមន័យដូចតទៅ៖

- សមាគមក្នុងស្រុក សំដៅដល់អង្គការសមាជិកភាព ដែលត្រូវបានបង្កើតឡើងក្រោមច្បាប់របស់កម្ពុជា ដោយរូបវន្តបុគ្គល ឬ/និងនីតិបុគ្គល ក្នុងគោលបំណងធ្វើជាតំណាង និងការពារផលប្រយោជន៍របស់សមាជិកខ្លួន ដោយមិនទាញយកចំណេញ ឬមិនយកកម្រៃមកចែកគ្នា ។
- អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក សំដៅដល់អង្គការមិនមែនសមាជិកភាពរួមទាំងមូលនិធិដែលត្រូវបានបង្កើតឡើងក្រោមច្បាប់របស់កម្ពុជា ដោយរូបវន្តបុគ្គល ឬ/និងនីតិបុគ្គល ក្នុងគោលបំណងផ្តល់មូលនិធិ ឬសេវាកម្មលើវិស័យមួយ ឬច្រើនដើម្បីបម្រើផលប្រយោជន៍សាធារណៈ ដោយមិនទាញយកចំណេញ ឬមិនយកកម្រៃមកចែកគ្នា ។
- សមាគមបរទេស ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស សំដៅដល់អង្គការស្របច្បាប់ដែលបង្កើតឡើងនៅក្រៅប្រទេស ក្នុងគោលបំណងធ្វើសកម្មភាពដើម្បីបម្រើផលប្រយោជន៍សាធារណៈ ដោយមិនទាញយកចំណេញ ។
- សមាគម សំដៅដល់សមាគមក្នុងស្រុក និងសមាគមបរទេស ។
- អង្គការមិនមែនរដ្ឋាភិបាល សំដៅដល់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

# ជំពូកទី ២
# ការបង្កើត និងការចុះបញ្ជីសមាគម និង
# អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

**មាត្រា ៥.-**

ការបង្កើតសមាគមក្នុងស្រុកតម្រូវឲ្យមានសមាជិកស្ថាបនិក ដែលជារូបវន្តបុគ្គលចំនួនយ៉ាងតិច ៣ (បី) រូប ដែលមានអាយុគ្រប់ ១៨(ដប់ប្រាំបី)ឆ្នាំ ឡើងទៅ ។

ការបង្កើតអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក តម្រូវឲ្យមានសមាជិកស្ថាបនិក ដែលជារូបវន្តបុគ្គលសញ្ជាតិខ្មែរចំនួនយ៉ាងតិច ៣ (បី) រូប ដែលម្នាក់ៗមានអាយុគ្រប់ ១៨ (ដប់ប្រាំបី)ឆ្នាំ ឡើងទៅ ។

**មាត្រា ៦.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកត្រូវចុះបញ្ជីនៅក្រសួងមហាផ្ទៃ ដោយបំពេញសំណុំលិខិតដូចខាងក្រោម ៖

១-ពាក្យសុំចុះបញ្ជីចំនួន ២(ពីរ) ច្បាប់

២-លិខិតបញ្ជាក់អាសយដ្ឋាននៃទីស្នាក់ការកណ្តាលរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកពីមេឃុំ ឬចៅសង្កាត់ចំនួន ១(មួយ)ច្បាប់

៣-ជីវប្រវត្តិរបស់ស្ថាបនិកម្នាក់ៗមានបិទរូបថតបច្ចុប្បន្នទំហំ ៤គុណនឹង៦ ចំនួន ២(ពីរ)ច្បាប់

៤-លក្ខន្តិកៈចុះហត្ថលេខាដោយប្រធានសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ចំនួន ២(ពីរ) ច្បាប់ ។

**មាត្រា ៧.-**

លក្ខន្តិកៈរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវមានខ្លឹមសារស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់នានាជាធរមាន ហើយត្រូវចែងចំណុចសំខាន់ៗដូចខាងក្រោម ៖

១-គោលបំណង និងគោលដៅ

២-ឈ្មោះជាអក្សរពេញ អក្សរកាត់ ដោយមិនត្រូវចម្លងតាមឈ្មោះជាអក្សរពេញ អក្សរកាត់របស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបានចុះបញ្ជីមុនរួចហើយ

៣-សញ្ញាសម្គាល់ មិនត្រូវចម្លងតាមសញ្ញាជាតិ ឬស្ថាប័នរដ្ឋ ឬរូបសញ្ញារបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបានចុះបញ្ជីមុនរួចហើយ ឬរូបសញ្ញាបដិរូបកាកបាទក្រហម ឬអឌ្ឍចន្ទក្រហម ឬស្ថាប័នអន្តរជាតិ

៤-វិធាននៃការជ្រើសរើស ការបញ្ឈប់ ការបណ្តេញចេញ ការផ្លាស់ប្តូរ ការដកហូតតំណែងប្រធាន ឬតំណែងនាយកប្រតិបត្តិ

៥-វិធាននៃការប្តូរឈ្មោះ ឬការប្តូរសញ្ញាសម្គាល់ ឬការធ្វើវិសោធនកម្មលក្ខន្តិកៈ

៦-ប្រភពធនធាន និងទ្រព្យសម្បត្តិ

៧-វិធាននៃការគ្រប់គ្រងធនធាន និងទ្រព្យសម្បត្តិ

៨-វិធាននៃការរំលាយ វិធាននៃការចាត់ចែងធនធាន និងទ្រព្យសម្បត្តិនៅពេលត្រូវបានរំលាយ ។

**មាត្រា ៨.-**

ក្រសួងមហាផ្ទៃត្រូវពិនិត្យសំណុំលិខិតស្នើសុំរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ហើយត្រូវសម្រេចព្រមទទួល ឬមិនព្រមទទួលចុះបញ្ជីរយៈពេលយ៉ាងយូរ ៤៥ (សែសិបប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ ។

ក្នុងករណីដែលអ្នកស្នើសុំមិនបានបំពេញគ្រប់លក្ខខណ្ឌសម្រាប់ការចុះបញ្ជី ក្រសួងមហាផ្ទៃត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកស្នើសុំឲ្យធ្វើការកែតម្រូវក្នុងរយៈពេលយ៉ាងយូរ ៤៥(សែសិបប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ ។ ក្រសួងមហាផ្ទៃត្រូវសម្រេចអំពីការចុះបញ្ជីក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃបានទទួលសំណុំលិខិតកែតម្រូវ ។

ក្នុងករណីក្រសួងមហាផ្ទៃខកខានមិនបានសម្រេចអំពីការចុះបញ្ជីក្នុងរយៈពេលដូចមានចែងក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ ខាងលើ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះត្រូវចាត់ទុកថា បានទទួលការចុះបញ្ជីស្របតាមច្បាប់នេះ ។ ក្នុងករណីនេះ ក្រសួងមហាផ្ទៃត្រូវធ្វើនិយតកម្មឯកសារចុះបញ្ជីផ្តល់ជូនទៅសាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះ ។

ក្រសួងមហាផ្ទៃអាចបដិសេធការស្នើសុំចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាដែលបានកេឃើញថា មានគោលបំណង និងទិសដៅដែលអាចធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមជាតិកម្ពុជា ។

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណា ដែលក្រសួងមហាផ្ទៃសម្រេចបដិសេធចំពោះការស្នើសុំចុះបញ្ជី មានសិទ្ធិប្តឹងទៅតុលាការ ។

**មាត្រា ៩.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក នឹងក្លាយជានីតិបុគ្គល ចាប់ពីថ្ងៃដែលក្រសួងមហាផ្ទៃបានចុះបញ្ជី ។ ក្រសួងមហាផ្ទៃត្រូវចម្លងឯកសារចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនេះទៅក្រសួងស្ថាប័នពាក់ព័ន្ធតាមការចាំបាច់ ។

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលមិនបានចុះបញ្ជី មិនត្រូវបានអនុញ្ញាតឲ្យធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ ។

LE ROYAUME DU CAMBODGE · LE MINISTÈRE DU PALAIS ROYAL

**មាត្រា ១០.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីព័ត៌មានពល់គណនីដែលត្រូវបើកសម្រាប់កិច្ចប្រតិបត្តិការរបស់ខ្លួននៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជាទៅក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃចុះបញ្ជី ។

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃ ក្នុងករណីមានការធ្វើវិសោធនកម្មលក្ខន្តិកៈ ឬការផ្លាស់ប្តូរទីស្នាក់ការ ឬការផ្លាស់ប្តូរតំណែងប្រធាន ឬតំណែងនាយកប្រតិបត្តិ ឬការប្រែប្រួលព័ត៌មានគណនីធនាគារ ក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃដែលផ្លាស់ប្តូរ ឬប្រែប្រួល ដោយភ្ជាប់មកជាមួយនូវសំណុំលិខិតដែលបានផ្លាស់ប្តូរ ។

**មាត្រា ១១.-**

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការបង្កើត និងការចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកសម្រាប់នីតិបុគ្គលនិងសម្រាប់ជនបរទេស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការបង្កើត និងការចុះបញ្ជីសមាគមសម្រាប់អនីតិជន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៣
## ការចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស

**មាត្រា ១២.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលមានបំណងធ្វើសកម្មភាពក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចុះបញ្ជីនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រោមទម្រង់ជាការចុះអនុស្សរណៈ ។

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលមានបំណងអនុវត្តគម្រោងរយៈពេលខ្លី ត្រូវសុំការអនុញ្ញាតពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិដោយផ្ទាល់ ឬតាមរយៈដៃគូក្នុងស្រុក ។

**មាត្រា ១៣.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលមានបំណងអនុវត្តគម្រោងនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ពាក្យសុំចុះអនុស្សរណៈនៅក្រសួងការបរទេស និងសហប្រតិបត្តិការ

អន្តរជាតិ ដោយភ្ជាប់មកជាមួយនូវសំណុំលិខិតដូចខាងក្រោម៖

១-លិខិតរបស់ប្រធានសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលមានទីស្នាក់ការអចិន្ត្រៃយ៍របស់ខ្លួននៅបរទេស ស្នើតែងតាំងតំណាងរបស់ខ្លួនដោយភ្ជាប់មកជាមួយនូវជីវប្រវត្តិសង្ខេបរបស់បុគ្គលដែលស្នើតែងតាំងចំនួន ១ (មួយ) ច្បាប់ និងស្នើបើកទីស្នាក់ការតំណាងចំនួន ១ (មួយ)ច្បាប់

២-លិខិតបញ្ជាក់អាសយដ្ឋាន នៃទីស្នាក់ការតំណាងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ពីមេឃុំ ឬចៅសង្កាត់ចំនួន ១ (មួយ) ច្បាប់

៣-លិខិតចេញដោយអាជ្ញាធរមានសមត្ថកិច្ចប្រទេសដើម អនុញ្ញាតឲ្យសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដំណើរការចំនួន ១ (មួយ) ច្បាប់

៤-លិខិតគាំទ្រគម្រោងនានារបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ចេញដោយអាជ្ញាធរសាធារណៈនៃព្រះរាជាណាចក្រកម្ពុជាចំនួន ១ (មួយ) ច្បាប់

៥-លិខិតបញ្ជាក់ពីចំនួនថវិកាសម្រាប់អនុវត្តគម្រោងនានារបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស រយៈពេលយ៉ាងតិច ៦ (ប្រាំមួយ) ខែ បញ្ជាក់ដោយទីស្នាក់ការអចិន្ត្រៃយ៍ខ្លួននៅបរទេសចំនួន ១ (មួយ) ច្បាប់

៦-លិខិតសន្យាផ្ដល់នូវរាល់គណនីនៃសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស នៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជាចំនួន ១ (មួយ) ច្បាប់ ។

**មាត្រា ១៤.-**

ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវពិនិត្យខ្លឹមសារនៃសំណុំលិខិត ហើយត្រូវសម្រេចយល់ព្រម ឬមិនយល់ព្រមចុះអនុស្សរណៈជាមួយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស យ៉ាងយូរ ៤៥ (សែសិបប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ ។

**មាត្រា ១៥.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសត្រូវធ្វើការពិភាក្សាឯកភាពជាមួយអាជ្ញាធរសាធារណៈដែលជាដៃគូលើគម្រោងនានា មុននឹងដាក់ពាក្យសុំចុះអនុស្សរណៈជាមួយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដូចមានចែងក្នុងចំណុចទី ៤ នៃមាត្រា ១៣ នៃច្បាប់នេះ ។

**មាត្រា ១៦.-**

អនុស្សរណៈមានសុពលភាពរយៈពេលយ៉ាងយូរ ៣ (បី) ឆ្នាំ ដោយផ្អែកតាមគម្រោងនានារបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ។ សុពលភាពអនុស្សរណៈនឹងត្រូវបញ្ចប់ជាស្វ័យប្រវត្តិក្រោយថ្ងៃផុតកំណត់ ។

ក្នុងករណីដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស មានបំណងបន្តសុពលភាពអនុស្សរណៈ ត្រូវដាក់ពាក្យសុំបន្តសុពលភាពអនុស្សរណៈឲ្យបាន ៩០ (កៅសិប) ថ្ងៃ មុនថ្ងៃផុតសុពលភាពអនុស្សរណៈ ។

**មាត្រា ១៧.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលបានចុះអនុស្សរណៈរួចហើយ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីព័ត៌មានរាល់គណនីដែលត្រូវបើកសម្រាប់កិច្ចប្រតិបត្តិការរបស់ខ្លួននៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជា ទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃចុះបញ្ជី ។

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងករណីមានការផ្លាស់ប្តូរទីស្នាក់ការ តំណាង ឬតំណាងប្រចាំប្រទេស ឬការប្រែប្រួលព័ត៌មានគណនីធនាគារ ក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃដែលផ្លាស់ប្តូរ ឬប្រែប្រួល ដោយភ្ជាប់មកជាមួយនូវសំណុំលិខិតដែលបានផ្លាស់ប្តូរ ។

## ជំពូកទី ៤

## ធនធាន និងទ្រព្យសម្បត្តិរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល

**មាត្រា ១៨.-**

ធនធាន និងទ្រព្យសម្បត្តិរបស់សមាគមក្នុងស្រុក មានដូចខាងក្រោម ៖

- ភាគទាន ឬវិភាគទាន ឬបរិវេសទានរបស់សមាជិក
- ធនធាន និងទ្រព្យសម្បត្តិផ្ទាល់របស់សមាគម
- អំណោយស្របច្បាប់ពីរូបវន្តបុគ្គល ឬនីតិបុគ្គល
- ចំណូលពីប្រភពស្របច្បាប់ផ្សេងៗទៀត ។

ធនធាន និងទ្រព្យសម្បត្តិរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មានដូចខាងក្រោម៖

- ធនធាន និងទ្រព្យសម្បត្តិផ្ទាល់របស់អង្គការ
- អំណោយស្របច្បាប់ពីរូបវន្តបុគ្គល ឬនីតិបុគ្គល
- ចំណូលពីប្រភពស្របច្បាប់ផ្សេងៗទៀត ។

**មាត្រា ១៩.-**

ធនធាន និងទ្រព្យសម្បត្តិរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ត្រូវបានមកពីប្រភពស្របច្បាប់នានា ។

# ជំពូកទី ៥
# សិទ្ធិ ផលប្រយោជន៍ និងភារកិច្ចរបស់សមាគម
# ឬអង្គការមិនមែនរដ្ឋាភិបាល

**មាត្រា ២០.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជី ឬអនុស្សរណៈ ត្រូវស្ថិតនៅក្រោមនីតិវិធីនៃបេបសារពើពន្ធជាធរមាន និងទទួលបានការលើកទឹកចិត្តនិងការអនុគ្រោះនានា ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ២១.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជី ឬចុះអនុស្សរណៈ មានសិទ្ធិចុះកិច្ចសន្យាសហប្រតិបត្តិការជាមួយដៃគូក្នុងការអនុវត្តគម្រោងសកម្មភាព ស្របតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២២.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជី ឬចុះអនុស្សរណៈ មានសិទ្ធិជ្រើសរើសបុគ្គលិក ឬកម្មករដើម្បីបម្រើការងារ ។ ការជ្រើសរើសនេះត្រូវអនុវត្តតាមច្បាប់ស្តីពីអន្តោប្រវេសន៍ ច្បាប់ស្តីពីការងារ និងលិខិតបទដ្ឋានគតិយុត្តនានានៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៣.-**

ទីស្នាក់ការតំណាងរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស បុគ្គលិកបរទេស និងបុគ្គលិកខ្មែរ រួមទាំងសមាជិកក្រុមគ្រួសាររបស់ខ្លួន ពុំទទួលបានអភ័យឯកសិទ្ធិនិងបុព្វសិទ្ធិជាអ្នកការទូត ដូចមានចែងក្នុងអនុសញ្ញាទីក្រុងវីយែនឆ្នាំ ១៩៦១ ស្តីពីទំនាក់ទំនងការទូតឡើយ ទាក់ទងនឹងសកម្មភាពបំពេញមុខងាររបស់ខ្លួន និងរឿងក្តីគ្រប់ប្រភេទ លើកលែងតែមានកិច្ចព្រមព្រៀងពិសេសរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ។

**មាត្រា ២៤.-**

អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អង្គការមិនមែនរដ្ឋាភិបាលបរទេស ឬសមាគមបរទេស ត្រូវប្រកាន់ជំហរអព្យាក្រឹតចំពោះគ្រប់គណបក្សនយោបាយនៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៥.-**

អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវផ្ញើទៅក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនូវរបាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមួយច្បាប់ មិនឲ្យហួសពីដំណាច់ខែកុម្ភៈនៃឆ្នាំបន្ទាប់ ។ ក្នុងករណីដែលទទួលបានការគាំទ្រហិរញ្ញវត្ថុពីម្ចាស់ជំនួយ អង្គការមិន

មែនរដ្ឋាភិបាលក្នុងស្រុកនោះត្រូវផ្ញើរបាយការណ៍ខាងលើ ដោយចម្លងចេញពីឯកសារដើមដែលផ្ញើទៅម្ចាស់ជំនួយ ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃផ្ញើទៅម្ចាស់ជំនួយ ព្រមទាំងឯកសារគម្រោងកម្មវិធីការងារ និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន ១ (មួយ) ច្បាប់ ដែលម្ចាស់ជំនួយបានយល់ព្រម ដោយចម្លងពីឯកសារដើម ឲ្យបានក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃម្ចាស់ជំនួយបានឯកភាពយល់ព្រម ។ របាយការណ៍នេះត្រូវតម្កល់ទុកនៅទីស្នាក់ការរបស់ខ្លួនរយៈពេលយ៉ាងតិច ៥(ប្រាំ) ឆ្នាំ ។

ក្នុងករណីចាំបាច់ ក្រសួងមហាផ្ទៃអាចស្នើសុំរបាយការណ៍ស្ដីពីសកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់សមាគម ។

អង្គការមិនមែនរដ្ឋាភិបាលបរទេសត្រូវផ្ញើទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវរបាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមួយច្បាប់ ចម្លងពីឯកសារដើមដែលផ្ញើទៅម្ចាស់ជំនួយក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃផ្ញើទៅម្ចាស់ជំនួយ ព្រមទាំងគ្រប់ឯកសារគម្រោងកម្មវិធីការងារ និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន ១ (មួយ) ច្បាប់ ដែលម្ចាស់ជំនួយបានយល់ព្រម ដោយចម្លងពីឯកសារដើមឲ្យបានក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃម្ចាស់ជំនួយបានឯកភាពយល់ព្រម ។

ក្នុងករណីចាំបាច់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬអាជ្ញាធរសវនកម្មជាតិ អាចធ្វើការត្រួតពិនិត្យ និងធ្វើសវនកម្មលើសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ។

## ជំពូកទី ៦

## ការផ្អាកសកម្មភាព ការរំលាយ ការបញ្ចប់សុពលភាពអនុស្សរណៈ ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល

### មាត្រា ២៦.-

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អាចផ្អាកសកម្មភាពរបស់ខ្លួន ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃ ។ មុននឹងផ្អាកសកម្មភាព សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកត្រូវធ្វើរបាយការណ៍សកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុ ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៥ នៃច្បាប់នេះ ។

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មុននឹងរំលាយត្រូវជម្រះកាតព្វកិច្ចតាមនីតិវិធី និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ២៧.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស អាចផ្អាកសកម្មភាពបានដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។ មុននឹងផ្អាកសកម្មភាព សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសត្រូវធ្វើរបាយការណ៍សកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុ ដូចមានចែងក្នុងកថាខណ្ឌទី ៣ នៃមាត្រា ២៥ នៃច្បាប់នេះ ។

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស មុននឹងបញ្ចប់សុពលភាពអនុស្សរណៈត្រូវជម្រះកាតព្វកិច្ចតាមនីតិវិធី និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ២៨.-**

ចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិដែលនៅសល់ពីការជម្រះកាតព្វកិច្ច ត្រូវអនុវត្តតាមលក្ខន្តិកៈរបស់ខ្លួន ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

ចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិដែលនៅសល់ពីការជម្រះកាតព្វកិច្ច ត្រូវអនុវត្តតាមអនុស្សរណៈ ឬកិច្ចព្រមព្រៀងជាមួយម្ចាស់ជំនួយ ។

**មាត្រា ២៩.-**

ចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលត្រូវបានរំលាយ ដោយសេចក្ដីសម្រេចរបស់តុលាការ ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីដោយសេចក្ដីសម្រេចរបស់ក្រសួងមហាផ្ទៃ ការជម្រះកាតព្វកិច្ច ព្រមទាំងការចាត់ចែងធនធាន និងទ្រព្យសម្បត្តិដែលនៅសល់ ត្រូវអនុវត្តតាមសេចក្ដីសម្រេចរបស់តុលាការ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន ។

ចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលត្រូវបានក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សម្រេចបញ្ចប់សុពលភាពអនុស្សរណៈមុនកាលកំណត់ ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិ ត្រូវអនុវត្តតាមសេចក្ដីសម្រេចរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលបានស្នើសុំបើកទីស្នាក់ការតំណាងនៅព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៧
## វិធានការរដ្ឋបាល និងទោសប្បញ្ញត្តិ

**មាត្រា ៣០.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលមិនបានអនុវត្តតាមមាត្រា ១០ ឬមាត្រា ២៤ ឬកថាខណ្ឌទី ១ ឬកថាខណ្ឌទី ២ នៃមាត្រា ២៥ នៃច្បាប់នេះ ក្រសួងមហាផ្ទៃត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដោយទុករយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ ។ ក្នុងករណីមិនអនុវត្តតាមការជូនដំណឹង ក្រសួងមហាផ្ទៃត្រូវជូនដំណឹង ជាលាយលក្ខណ៍អក្សរផ្អាកសកម្មភាពជា

បណ្តោះអាសន្នរយៈពេលយ៉ាងយូរ ៩០ (កៅសិប) ថ្ងៃ ។ ក្នុងករណីនៅតែមិនព្រមអនុវត្ត ក្រសួងមហាផ្ទៃត្រូវសម្រេចជាលាយលក្ខណ៍អក្សរលុបឈ្មោះចេញពីបញ្ជី ។

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលមិនបានអនុវត្តត្រឹមត្រូវតាមលក្ខន្តិកៈរបស់ខ្លួន ក្រសួងមហាផ្ទៃត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬផ្អាកសកម្មភាពជាបណ្តោះអាសន្ន ដោយទុករយៈពេលយ៉ាងយូរ ៣០(សាមសិប) ថ្ងៃ ។ ក្នុងករណីនៅតែមិនព្រមអនុវត្ត ក្រសួងមហាផ្ទៃត្រូវសម្រេចជាលាយលក្ខណ៍អក្សរលុបឈ្មោះចេញពីបញ្ជី ។

ក្រសួងមហាផ្ទៃត្រូវសម្រេចលុបឈ្មោះចេញពីបញ្ជីចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាដែលធ្វើសកម្មភាពប៉ះពាល់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមជាតិកម្ពុជា ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។

**មាត្រា ៣១.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មានសិទ្ធិប្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃទាក់ទងនឹងការមិនចុះបញ្ជី ការបញ្ឈប់សកម្មភាព ការលុបឈ្មោះចេញពីបញ្ជី និងការពិន័យទៅតុលាការ ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃជូនដំណឹងអំពីសេចក្តីសម្រេច ។

**មាត្រា ៣២.-**

អាជ្ញាធរមានសមត្ថកិច្ច ត្រូវចាត់វិធានការបញ្ឈប់ជាបន្ទាន់ចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាដែលធ្វើសកម្មភាពដោយមិនបានចុះបញ្ជីនៅក្រសួងមហាផ្ទៃស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។ ក្នុងករណីមិនរាងចាល សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះ ត្រូវពិន័យជាប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ដោយក្រសួងមហាផ្ទៃ ។ ក្នុងករណីនៅតែបន្តធ្វើសកម្មភាពបន្តទៀត អាជ្ញាធរមានសមត្ថកិច្ចត្រូវប្តឹងទៅតុលាការ ដើម្បីចាត់វិធានការតាមច្បាប់ ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។

បទប្បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណា ដែលត្រូវបានក្រសួងមហាផ្ទៃលុបឈ្មោះចេញពីបញ្ជី ឬផ្អាកសកម្មភាព ហើយនៅតែបន្តធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣៣.-**

ក្នុងករណីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលមិនបានអនុវត្តតាមមាត្រា ១៧ ឬមាត្រា ២៤ ឬកថាខណ្ឌទី៣ នៃមាត្រា ២៥ នៃច្បាប់នេះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដោយទុករយៈពេលយ៉ាងយូរ ៣០ (សាមសិប)ថ្ងៃ ។ ក្នុងករណីមិនអនុវត្ត ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវព្រមានជាលាយលក្ខណ៍អក្សរដោយទុករយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ ។ ក្នុងករណីនៅតែមិនព្រមអនុវត្តតាមការព្រមាន ក្រសួង

ការបរទេស និងសហប្រតិបត្តិការអន្តរជាតិត្រូវសម្រេចជាលាយលក្ខណ៍អក្សរបញ្ចប់សុពលភាពអនុស្សរណៈ ។

**មាត្រា ៣៤.-**

អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការបញ្ឈប់ជាបន្ទាន់ ចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសណាដែលធ្វើសកម្មភាពដោយមិនបានចុះបញ្ជី ឬដែលត្រូវបានបញ្ចប់សុពលភាពអនុស្សរណៈដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។ វិធានការបន្ថែមទាក់ទង នឹងការបណ្តេញចេញស្របតាមច្បាប់អន្តោប្រវេសន៍ អាចត្រូវបានអនុវត្តចំពោះជនបរទេសណា ដែលបម្រើការងារនៅក្នុងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលប្រព្រឹត្តល្មើសខាងលើ ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។

**មាត្រា ៣៥.-**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អាចបញ្ចប់សុពលភាពអនុស្សរណៈ ក្នុងករណីដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស អនុវត្តមិនបានត្រឹមត្រូវតាមអនុស្សរណៈដែលចុះជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬក្នុងករណីដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសធ្វើសកម្មភាពប៉ះពាល់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមជាតិកម្ពុជា ។

**មាត្រា ៣៦ .-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលណា ដែលសកម្មភាពរបស់ខ្លួនធ្វើឲ្យប៉ះពាល់ដល់សន្តិសុខជាតិ ឬមានការពាក់ព័ន្ធនឹងការសំអាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម ឬបទល្មើសភេរវកម្ម ឬបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ត្រូវផ្តន្ទាទោសដោយយោងតាមច្បាប់ព្រហ្មទណ្ឌជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៨
## អន្តរប្បញ្ញត្តិ

**មាត្រា ៣៧.-**

បន្ទាប់ពីច្បាប់នេះចូលជាធរមាន សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបានតម្កល់សំណុំលិខិតនៅក្រសួងមហាផ្ទៃរួចហើយ ត្រូវចាត់ទុកថាបានចុះបញ្ជី និងទទួលបានជាស្វ័យប្រវត្តិនូវឋានៈជានីតិបុគ្គលស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៣៨.-**

បន្ទាប់ពីច្បាប់នេះចូលជាធរមាន សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលបានចុះអនុស្សរណៈជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិរួចហើយ ត្រូវចាត់ទុកថាបានចុះបញ្ជីស្របតាមច្បាប់នេះ និងអាចធ្វើសកម្មភាពរហូតដល់ថ្ងៃផុតកំណត់សុពលភាពអនុស្សរណៈ ។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

**មាត្រា ៣៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសាផ្ទុយពីច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០១៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣០៧. ១៥០៧. ៧០៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ហត្ថលេខា**
**សម្តេចក្រឡាហោម ស ខេង**

លេខៈ ៧៤៧ស.ណ
**សំណៅដែលមានគំរូថតចម្លងជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**